*របាយការណ៍ៈ*

# ខ្មែរក្រហម៧រូបប្រឈមមុខនឹងការកាត់ទោស

២១ឆ្នាំក្រោយពីការដួលរលំនៃរបបខ្មែរក្រហម អ្នកជំនាញការពីររូបដែលជាអ្នកនិពន្ធរួមផ្នែកសិក្សាស្រាវជ្រាវជាន់ខ្ពស់អំពីកម្ពុជាគឺ ស្ទីវ ហេដឌ័រ និងអ្នកជំនាញការច្បាប់សិទ្ធិមនុស្សអន្តរជាតិ ប្រែអ៊ិន ទិតម័រ បានសរសេរនូវរបាយការណ៍មួយដោយធ្វើការវាយតម្លៃជាលើកដំបូងបង្អស់ទៅលើពិរុទ្ធភាពរបស់បុគ្គលមួយចំនួន ។

របាយការណ៍នេះមានចំណងជើងថា "បុគ្គល៧រូបដែលត្រូវកាត់ទោសៈ ការដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម" ។ របាយការណ៍គឺជាឯកសារប្រវត្តិសាស្ត្រមួយដែលមិនត្រឹមតែកត់ត្រានូវអំពើឃោរឃៅដែលប្រព្រឹត្តឡើងនៅក្នុងរបបកាន់អំណាចដ៏ខ្មៅងងឹតរបស់ខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបញ្ជាក់អំពីការដឹងឮរបស់មេដឹកនាំ និងអំពីការទទួលខុសត្រូវលើបទព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ។

ដោយផ្អែកលើភស្តុតាងឯកសារដែលទើបតែស្រាវជ្រាវរកឃើញថ្មីៗដែលត្រូវបានពិនិត្យរួចហើយ មានបញ្ជាក់អំពីនយោបាយមហាឃាតកម្មបង្កើតឡើងដោយថ្នាក់លើដែលមានអំណាចបំផុតនិងអនុវត្តតាមរយៈខ្សែសង្វាក់នៃការបញ្ជា ។

ភស្តុតាងទាំងនេះរួមមាន ឯកសារទូរសា កំណត់ហេតុប្រជុំបក្សរបាយការណ៍ពីកន្លែងសម្លាប់និងគុកដែលត្រូវបានផ្ញើឲ្យជនដែលសង្ស័យទាំង៧នាក់ដែលត្រូវកាត់ទោស ថែមទាំងសៀវភៅកំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហមនិងចម្លើយសារភាពរបស់"កម្មាភិបាល" ខ្មែរក្រហមដែលត្រូវបានធ្វើទារុណកម្មនិងសម្លាប់ចោលក្រោយពីត្រូវបានដកចេញពីមុខតំណែង ព្រមទាំងបទសម្ភាសន៍របស់មេដឹកនាំថ្នាក់លើដែលរួមមានកិច្ចសន្ទនារបស់ ស្ទីវ ហេដឌ័រ ផ្ទាល់ ជាមួយ អៀង សារី ទៀតផង ដែលបានបង្ហាញអំពីខ្សែសង្វាក់ដែលមិនមានអ្នកណាស្រាវជ្រាវរកឃើញពីមុនមករវាងអំពើឃោរឃៅនានាដែលប្រព្រឹត្តនៅថ្នាក់ក្រោមជាមួយកម្មាភិបាលដែលមានឈ្មោះនៅក្នុងរបាយការណ៍នេះ ។

របាយការណ៍នេះសង្កត់ធ្ងន់លើការសម្លាប់ជាទ្រង់ទ្រាយធំទៅលើក្រុមដែលជាមុខសញ្ញាចំនួនបីគឺៈ ទីមួយ អ្នកដែលជាប់និន្នាការជាមួយអតីតរបបសាធារណរដ្ឋដែលខ្មែរក្រហមផ្តួលរំលំនៅក្នុងឆ្នាំ១៩៧៥ ។ ទីពីរ បក្ខជនឬ "កម្មាភិបាល" នៅក្នុងជួរខ្មែរក្រហមដែលត្រូវបានសង្ស័យថាជាជនក្បត់ ។ ទីបី សមាជិករបស់ក្រុមមិនមែនកុម្មុយនិស្តជាប្រជាជនទូទៅ ។

បុគ្គលទាំង៧នាក់ដែលមានក្នុងរបាយការណ៍នេះរួមមានថ្នាក់ដឹកនាំនៅក្បៀកស្និទ្ធនឹង ប៉ុល ពត ដែលនៅរស់រានមានជីវិតសព្វថ្ងៃនេះ រួមមាន ÷

◆ នួន ជា (បងលេខ២) ជាអនុរបស់ ប៉ុល ពត និងជាសមាជិកបង្គោលគណៈកម្មាធិការមជ្ឈិមដ៏មានអំណាចរបស់ខ្មែរក្រហមដែលបានបង្កើតនិងអនុវត្តនយោបាយសម្លាប់មនុស្ស ។

◆ អៀង សារី ជារដ្ឋមន្ត្រីក្រសួងការបរទេសដែលបានជំរុញនិងជួយជ្រោមជ្រែងជាសាធារណៈឲ្យមានការចាប់ខ្លួននិងការសម្លាប់កម្មាភិបាលនៅក្នុងជួរក្រសួងរបស់ខ្លួន ។

◆ ខៀវ សំផន ជាគណៈប្រធានរដ្ឋដែលបានជម្រុញមន្ត្រីបក្សថ្នាក់ក្រោមឲ្យសម្លាប់ជនរងគ្រោះ ។

◆ ម៉ុក ជាលេខាបក្សភូមិភាគនិរតីដែលជាអ្នកបញ្ជានិង(ឬ) ជួយជ្រោមជ្រែងក្នុងការចាប់ខ្លួនអ្នកនៅថ្នាក់ក្រោមនៅក្នុងភូមិភាគដែលត្រូវបានសង្ស័យថាក្បត់ ហើយមិនបានទប់ស្កាត់ឬដាក់ទណ្ឌកម្មចំពោះអំពើឃោរឃៅដែលប្រព្រឹត្តឡើងដោយកូនចៅក្រោមបង្គាប់ខ្លួនផ្ទាល់ ។

◆ កែ ពក លេខាបក្សភូមិភាគឧត្តរ-កណ្តាលដែលបានបញ្ជានិង(ឬ) ជម្រុញឲ្យមានការចាប់ខ្លួនបក្ខពួកក្បត់ដែលជាប់សង្ស័យនៅភូមិភាគរបស់ខ្លួន និងមិនបានទប់ស្កាត់ឬដាក់ទណ្ឌកម្មដល់អំពើឃោរឃៅដែលប្រព្រឹត្តឡើងដោយកូនចៅនៅក្រោមបង្គាប់ខ្លួនផ្ទាល់ ។

◆ ស៊ូ ម៉េត និង មាស មុត ជាប្រធានយោធាដែលមានតួនាទីចុះចាប់និងបញ្ជូនកូនចៅទៅសួរចម្លើយនិងសម្លាប់ចោល ។

របាយការណ៍នេះចងក្រងជាឯកសារយ៉ាងលម្អិតអំពីតួនាទីដែលបុគ្គលខាងលើបានជម្រុញនិងអនុវត្តនូវនយោបាយមនុស្សឃាតមានជាអាទិ៍ដូចជាតាមរយៈការចូលប្រជុំរៀបចំគម្រោងសម្លាប់មនុស្ស ហើយរៀបរាប់អំពីសកម្មភាពរបស់បុគ្គលទាំង៧រូប និងធ្វើការវាយតម្លៃ




ទៅលើអ៊ីដែលបុគ្គលម្នាក់ៗខាងលើបានដឹងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយកូនចៅនៅក្រោមបង្គាប់ខ្លួន ពោលគឺជាការដឹងឮដែលជនសង្ស័យទាំងនេះមួយចំនួនបានបដិសេធជាយូរណាស់មកហើយ ។

ភ័ស្តុតាងដែលបង្ហាញថាបុគ្គលខាងលើជាអ្នកបានទទួលរបាយ-ការណ៍និងឯកសារផ្សេងៗស្តីអំពីដំណើរការវិវត្តទៅមុខនៃអំពើឃោរឃៅ ហើយមិនបានការពារថា ប៉ុល ពត ដែលបានស្លាប់ហើយនោះមិនទទួលខុសត្រូវក្នុងការរៀបចំនិងអនុវត្តនយោបាយឃោរឃៅរបស់ខ្មែរក្រហមឡើយ ។

ពេលនេះ អ្នកដែលមានការទទួលខុសត្រូវខ្ពស់បំផុតក្នុងការសម្លាប់ប្រជាជនកម្ពុជាជិតមួយភាគបី នៅក្នុងការគ្រប់គ្រងអំណាចរបស់ខ្មែរក្រហម ប្រាកដជាមិនអាចនិយាយថាខ្លួនមិនដឹងតទៅទៀតបានឡើយ ។ ការចេញផ្សាយនូវរបាយការណ៍នេះស្របគ្នាទៅនឹងកិច្ចប្រឹងប្រែងនានាដែលកំពុងបន្តធ្វើដោយអង្គការសហប្រជាជាតិ ប្រទេសដែលពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជានិងគ្រប់ទិសទី ក្នុងការបង្កើតនូវតុលាការឧក្រិដ្ឋកម្មមួយដើម្បីយកអ្នកដែលទទួលខុសត្រូវមកកាត់ទោសចំពោះមុខច្បាប់ ។

របាយការណ៍នេះអាចជាគ្រឹះក្នុងការកសាងសំណុំរឿងព្រហ្មទណ្ឌដូចដែលកំពុងតែធ្វើសព្វថ្ងៃនេះដើម្បីដាក់បន្ទុកចោទប្រកាន់លើបុគ្គលទាំង៧រូបខាងលើ ព្រមទាំងកម្មាភិបាលខ្មែរក្រហមផ្សេងៗទៀតដែលនៅរស់ ដោយយោងទៅតាមភ័ស្តុតាងដែលមានស្រាប់និងរៀបចំឡើង ប្រយោជន៍ដើម្បីជួយផ្តល់ឲ្យប្រជាជនកម្ពុជានូវអ្វីដែលជាឱកាសចុងក្រោយក្នុងការកាត់ទោសក្រុមថ្នាក់ដឹកនាំរបស់ ប៉ុល ពត ដែលនៅរស់រានមានជីវិតនិងមានវ័យកាន់តែចាស់ជរាហើយនោះ ។

**ស្វ ប៊ុនស៊ូ**

# រឿងរ៉ាវនៃការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស

**(តចប់)** នៅថ្ងៃទី១២ ខែកញ្ញា ខ្ញុំបានអញ្ជើញអ្នកទាំងនោះត្រូវឲ្យវិលត្រឡប់មកវិញនៅខែមករា ក្រោយពីពេលដែលយើងបានបញ្ចប់ការចងក្រងឯកសារខ្មែរក្រហមទាក់ទងនឹងអំពើប្រល័យពូជសាសន៍ជូនដល់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។ មជ្ឈមណ្ឌលឯកសារកម្ពុជាដោយមានការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសំណាក់ ស៊ី.ដី.ភី ពេលនោះមានសេរីភាពក្នុងការបម្រើការចាំបាច់ផ្សេងៗរបស់មន្ទីរបញ្ចកោណ ។ នៅថ្ងៃទី២៣ ខែមករា បេម ដាប់ប៊ែលយូ វ៉ូល មកពីផ្នែក អឹម.អាយ.អេ របស់ក្រសួងការពារជាតិ បានទទួលយកសំណើរបស់ខ្ញុំ ។ ខ្ញុំបានឆ្លើយតបវិញនៅថ្ងៃទី២៥ ខែតុលា ដោយបញ្ជាក់ជាថ្មីម្តងទៀតចំពោះឧត្តមសេនីយ វ៉ូល ថា អ្នកសិក្សាស្រាវជ្រាវរបស់លោកឈ្មោះដេវីត ឆេនដល័រ ត្រូវបានស្វាគមន៍ឲ្យធ្វើការនៅបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងខែមករា-កុម្ភៈឆ្នាំ១៩៩៧ ។ ការិយាល័យរបស់ វ៉ូល បានទូរស័ព្ទនៅពេលរសៀលថ្ងៃនោះមកអរគុណខ្ញុំ ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកក៏អរគុណខ្ញុំដូចជា ឆេនដល័រ ដែរ ។

បីថ្ងៃក្រោយមក នៅថ្ងៃទី២៩ខែតុលា នៅក្នុងទិនានុប្បវត្តិអេស៊ាន វ៉លស្ទ្រីត ស្ទ៊ីត ចោទប្រកាន់ខ្ញុំខុសថាខ្ញុំមិនព្រមធ្វើកិច្ចសហប្រតិបត្តិការជាមួយអ្នកសិក្សាស្រាវជ្រាវរបស់ក្រសួងការពារប្រទេស ។ ខ្ញុំបានឆ្លើយតបវិញតាមទូរសារនៅថ្ងៃទី៤ ខែវិច្ឆិកា ប៉ុន្តែសារពត៌មានរបស់ ស្ទ៊ីត បដិសេធមិនហ៊ានចេញផ្សាយនូវការឆ្លើយតបរបស់ខ្ញុំនេះ ដោយបន្តផ្ញើទៅឲ្យទិនានុប្បវត្តិ